ទីស្ដីការ ក្រសួងយុត្តិធម៌

លេខ ០៣ ក.រ-៩៣

# សាធារណរដ្ឋប្រជាមានិតកម្ពុជា

## ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ជម្រាបមក

-ឯកឧត្តម ប្រធានតុលាការកំពូល

-ឯកឧត្តម អគ្គរដ្ឋអាជ្ញាអមតុលាការកំពូល

-លោក ប្រធានសាលាឧទ្ធរណ៍

-លោក អគ្គរដ្ឋអាជ្ញាសាលាឧទ្ធរណ៍

-លោក ប្រធានតុលាការខេត្ត ក្រុង

-លោក ប្រធានតុលាការយោធា

-លោក រដ្ឋអាជ្ញាអមតុលាការយោធា

**កម្មវត្ថុ:** ការអនុវត្តន៍ច្បាប់ ស្ដីពីប្រាក់ប្រដាប់ក្ដី ។

ខ្ញុំសូមជម្រាបថា ច្បាប់ស្ដីពីប្រាក់ប្រដាប់ក្ដីត្រូវបានប្រកាសឲ្យប្រើរួចហើយក្រោយពីច្បាប់នេះបានត្រូវប្រកាសឲ្យប្រើ តុលាការខេត្ត ក្រុង បានទទួលការណែនាំផ្ទាល់ពីក្រសួងអំពីបែបបទសម្រាប់អនុវត្តរួចហើយដែរ ។ ក្រសួងយុត្តិធម៌មានជំនឿថា តុលាការខេត្ត ក្រុង ប្រាកដជាអនុវត្តបានល្អហើយ ។ដើម្បីបញ្ជាក់ឲ្យយល់រឹតតែច្បាស់តទៀវនេះ ក្រសួងសូមណែនាំ នឹងរំលឹកឡើងវិញនូវប្រកាសមួយចំនួនដែលត្រូវប្រតិបត្តិតាមដូចតទៅ៖

**អំពីការបង់ប្រាក់ប្រដាប់ក្ដី នៅតុលាការខេត្ត ក្រុង**

ក្នុងរឿងរដ្ឋប្បវេណី ពាណិជ្ជកម្ម វិវាទរដ្ឋបាល និងវិវាទការងារតាមនីតិវិធី តុលាការត្រូវធ្វើការផ្សះផ្សារសិនក្នុងករណីដែលគូក្ដីមិនសះជាគ្នាទេ ទើបឲ្យគូក្ដីបង់ប្រាក់ប្រដាប់ក្ដីតាមច្បាប់ គឺចាប់ពីពេលនោះហើយដែលតុលាការមានអំណាចធ្វើអង្កេតចាត់ការនិងដាក់រឿងជំនុំជម្រះបាន។តែបើអ្នកប្ដឹងមិនបានបង់ប្រាក់ប្រដាប់ក្ដីទេតុលាការគ្មានអំណាចចាត់ការ និងដាក់រឿងជំនុំជម្រះបានទេ លើកលែងតែក្នុងករណីដែលបានទទួលការអនុគ្រោះពីតុលាការនៅក្នុងលក្ខខណ្ឌដែលច្បាប់បានកំណត់ ។

ក្នុងករណីរឿងអង្គសេចក្ដីដែលមានទំនាក់ទំនង នឹងកិច្ចការប្រញាប់ គូក្ដីអាចស្នើសុំបង់ប្រាក់ប្រដាប់ក្ដីភ្លាមៗបានដែរ នៅពេលគេដាក់ពាក្យបណ្ដឹង ។ឯការផ្សះផ្សាវិញត្រូវធ្វើតាមនីតិវិធីដដែលឥតតបញ្ឈប់ទេ ។

ដើមបណ្ដឹងត្រូវបង់ប្រាក់ប្រដាប់ក្ដីជាដំបូង ៧០០០ រៀល ។ប្រាក់នេះត្រូវដើបណ្ដឹងបង់នៅក្រឡាបញ្ជីកាន់ហឹបប្រាក់ ។ក្រឡាបញ្ជីកាន់ហឹបប្រាក់ត្រូវចេញបង្កាន់ដៃទៅឲ្យអ្នកបង់ ។ នីតិវិធីទូទាត់ចំណាយប្រាក់នេះមានដូចតទៅ៖

## ពន្ធចុះបញ្ជីក្តី

នៅពេលចុះបញ្ជីក្តី នៅក្នុងសៀវភៅដែលមានលេខ........ថ្ងៃ....ខែ.....ឆ្នាំ....សំណុំរឿងចុះឈ្មោះគូក្តី និងកម្មវត្ថុបណ្តឹង ក្រឡាបញ្ជីកាន់ហិបប្រាក់ត្រូវកាត់យកពន្ធចុះបញ្ជីក្តីជាប្រាក់ចំនួន ១០០០ រៀល ។ក្នុងប្រាក់នេះត្រូវយកទៅដាក់ឃ្លាំងចំនួន ៩០០រៀល និងបានជាប្រយោជន៍ក្រឡាបញ្ជីកាន់ហិបប្រាក់ ១០០ រៀល ។

ចំពោះពន្ធចុះបញ្ជីក្តីនេះ មិនត្រូវបង្វិលឲ្យដើមបណ្តឹងវិញទេ ទោះជាតុលាការបានចំណាយរឿងនោះចោលក៏ដោយ ។ក្រឡាបញ្ជីកាន់ហិបប្រាក់ត្រូវតែធ្វើបញ្ជីទូទាត់ពន្ធចុះបញ្ជីក្តីដែលត្រូវដាក់ឃ្លាំង និងត្រូវបានជាប្រយោជន៍ក្រឡាបញ្ជីដោយខានមិនបាននៅដំណាច់ខែនីមួយៗ ដោយមិនចាំបាច់រងចាំសេចក្តីសម្រេចរបស់តុលាការទេ ។

ជារៀងរាល់ខែក្រឡាបញ្ជីក៏ត្រូវផ្ញើបញ្ជីនេះ ជូនមកក្រសួងយុត្តិធម៌មួយច្បាប់ផងដែរ ដើម្បីក្រសួងពិនិត្យនិងតាមដានអំពីសកម្មភាពទាំងនោះ ។

## ពន្ធផ្ទេរក្តី

## ពន្ធផ្ទេរក្តីនេះត្រូវបានចែកជាពីរ គឺ៖

១-ពន្ធហ្នឹង មិនប្រែប្រួល

២-ពន្ធសមាមាត្រ

ចំពោះពន្ធហ្នឹង ជាគោលការណ៍ត្រូវទូទាត់កាត់យកក្នុងប្រាក់ប្រដាប់ក្តីដែលបានបង់ជាដំបូងនោះ ប៉ុន្តែអាចនិងទូទាត់បានលុះត្រាតែតុលាការបានសម្រេចសេចក្តីហើយសិន ។ ដោយឡែកប្រាក់នេះត្រូវបង្វិលឲ្យដើមបណ្តឹងវិញក្នុងករណីដែលតុលាការបានចំណាយរឿងចោល ។តែបើតុលាការបានសម្រេចក្រៅពីការចំណាយរឿងចោលទោះជាមានបណ្តឹងតវ៉ាក្តី ឬ គ្មានបណ្តឹងតវ៉ាក្តី ក្រោយពីតុលាការបានសម្រេចសេចក្តីហើយ ក្រឡាបញ្ជីត្រូវធ្វើបញ្ជីត្រូវធ្វើបញ្ជីទូទាត់ពន្ធហ្នឹងនេះ ដោយយកទៅដាក់ក្នុងឃ្លាំងចំនួន ៩០០ រៀល និងបានជាប្រយោជន៍ក្រឡាបញ្ជីកាន់ហិបប្រាក់ ១០០ រៀល នៅក្នុងដំណាច់ខែនីមួយៗ ដូចគ្នានឹងពន្ធចុះបញ្ជីក្តីដែរ ។ បញ្ជីទូទាត់ប្រាក់ពន្ធហ្នឹងនេះត្រូវផ្ញើជូនមកក្រសួងយុត្តិធម៌មួយច្បាប់ជារៀងរាល់ខែ ដើម្បីឲ្យក្រសួងពិនិត្យ ។

ចំពោះពន្ធសមាមាត្រវិញ មិនត្រូវឲ្យគូក្តីបង់ទុកជាមុនទេ ហើយក៏មិនត្រូវកាត់ទូទាត់ជាមួយនឹងប្រាក់ប្រដាប់ក្តីដែលបង់ជាដំបូងនោះដែរ ។ប្រាក់នេះអាចទូទាត់បានលុះត្រាតែសាលក្រមមានអនុភាពអនុវត្តហើយដែលត្រូវបង្គាប់ឲ្យគូក្តីបង់ គឺនៅពេលដែលគូក្តីនោះសុំចម្លងសាលក្រមយកទៅអនុវត្ត ។ប្រសិនបើគូក្តីមិនព្រមបង់ពន្ធសមាមាត្រនេះទេ ក្រឡាបញ្ជីមិនត្រូវចេញសេចក្តីសម្លងសាលក្រមឲ្យទៅគូក្តីឡើយ ។

ពន្ធសមាមាត្រនេះ បើបង់នៅខែណា ក្រឡាបញ្ជីត្រូវធ្វើបញ្ជីទូទាត់នៅក្នុងខែនោះដោយត្រូវញែកដាក់ឃ្លាំង ៨០ ភាគរយ និងដាក់ក្នុងហិបប្រាក់ក្រឡាបញ្ជីទូទាំងប្រទេស ២០ ភាគរយ ។

ក្រឡាបញ្ជីកាន់ហិបប្រាក់មិនអាចដកយកពន្ធសមាមាត្រនេះជាប្រយោជន៍របស់ខ្លួនដូចជាពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងបានឡើយ ។

បញ្ជីទូទាត់ពន្ធសមាមាត្រនេះ ត្រូវផ្ញើជូនមកក្រសួងយុត្តិធម៌ជារៀងរាល់ខែដែរ ដើម្បីក្រសួងមានលទ្ធភាពត្រួតពិនិត្យ ។

## អំពីប្រាក់ចំណាយក្នុងកិច្ច ស៊ើបសួរ

ប្រាក់ចំណាយក្នុងកិច្ចស៊ើបសួរ ជាគោលការណ៍ត្រូវដកយកពីប្រាក់ប្រដាប់ក្តី ដែលបានបង់ជាដំបូងនោះ។ ហើយអាចដក់ចំណាយបានតែទៅលើការប្រគល់ដីកាកោះ ទៅលើសាក្សី ទៅលើអាជ្ញាកណ្តាល ទៅលើកោសល្យវិច័យ និងទៅលើអាជ្ញាធរតុលាការដែលជូនទៅពិនិត្យដល់ទីកន្លែងតែប៉ុណ្ណោះ ។ក្រៅពីនេះពុំអាចដកយកទៅចាយបានទេ ។

ក្នុងប្រាក់ដែលបានបង់ជាដំបូងនេះ បើចាយមិនអស់ត្រូវប្រគល់ឲ្យដើមបណ្ដឹងវិញ តែបើការចំណាយមានចំនួនច្រើនលើសពីប្រាក់ដែលគេបង់ ក្រឡាបញ្ជីដែលទទួលកិច្ចការនេះត្រូវបង្គាប់ឲ្យគូក្ដីបង់បន្ថែមឲ្យបានមុនតុលាការជំនុំជម្រះ ។

-ការចំណាយទៅលើអាជ្ញាកណ្ដាល ទៅលើកោសល្យវិច័យទៅលើអាជ្ញាធរតុលាការដែលបានទៅពិនិត្យដល់ទីកន្លែង លុះត្រាតែមានដីកា ឬ សាលក្រមរបៀបរបស់តុលាការចាត់ឲ្យធ្វើទើបអ្នកទាំងនោះមានសិទ្ធិដកយកប្រាក់ចំណាយនោះបាន ។ប្រសិនបើគ្មានទេអ្នកទាំងនោះគ្មានសិទ្ធិដកយកប្រាក់នេះបានទេ ។

-ឯការចំណាយទៅលើដីកាកោះ និងលើសាក្សីវិញ នឹងអាចធ្វើទៅបានលុះត្រាតែអ្នកប្រគល់ដីកាកោះបានប្រគល់ដីកាកោះនោះដល់ទីកន្លែង ឬទីលំនៅរបស់គេ និងសាក្សីវិញលុះណាតែសាក្សីនោះចូលមកចំពោះមុខតុលាការតាមការអញ្ជើញ ទើបអ្នកទាំងនោះមានសិទ្ធិដកយកប្រាក់ខាងលើនេះបាន ។

**អំពីការបង់ប្រដាប់ក្ដី នៅសាលាឧទ្ធរណ៍ និងតុលាការកំពូល**

ជាគោលការណ៍ នៅសាលាឧទ្ធរណ៍ និងតុលាការកំពូល ក្រោយពីបានជំនុំជម្រះក្ដីនៅការិយាល័យក្រឡាបញ្ជីនៃសាលានីមួយៗ គឺៈ

១-សាលាឧទ្ធរណ៍ បង់ជាដំបូង ១៣០០ រៀល

២-តុលាការកំពូលបង់ជាដំបូង ១៩០០០ រៀល

-ឯការដកចំណាយក៏ត្រូវអនុវត្តដូចគ្នា និងតុលាការខេត្ត ក្រុង ដែរ គ្រាន់តែខុសចំនួនទឹកប្រាក់ដែលត្រូវចំណាយតែប៉ុណ្ណោះគឺៈ

**សាលាឧទ្ធរណ៍**

១-ពន្ធចុះបញ្ជីក្ដី ១.៥០០ រៀល ដោយត្រូវដាក់ឃ្លាំង ១.២៧៤ រៀល នឹងរង្វាន់ក្រឡាបញ្ជីកាប់ហឹបប្រាក់ ២២៥ រៀល ។

២-ពន្ធហ្មឹង ១.៥០០ រៀល ដោយត្រូវដាក់ឃ្លាំង ១.២៧៤ រៀល នឹងរង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ ២២៤ រៀល ។

៣-ប្រាក់បម្រុងចំនួន ១០.០០០ រៀល ។

**តុលាការកំពូល**

១-ពន្ធចុះបញ្ជីក្ដី ២.០០០ រៀល ដោយត្រូវដាក់ឃ្លាំង ១.៦០០ រៀល នឹងរង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ ៤០០ រៀល ។

២-ពន្ធហ្មឹង ២.០០០ រៀល ដោយត្រូវដាក់ឃ្លាំង ១.៦០០ រៀល នឹងរង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ ៤០០ រៀល ។

៣-ប្រាក់បម្រុង ចំនួន ១៥.០០០ រៀល ។

ពន្ធសមាមាត្រ និងប្រាក់ចំណាយក្នុងកិច្ចស៊ើបសួរ ក៏ត្រូវអនុវត្តតាមទម្រង់ការតែមួយដូចគ្នានឹងតុលាការខេត្ត ក្រុង ដែរ ។

គ្រប់ការទូទាត់ចំណាយប្រាក់ប្រដាប់ក្ដី ត្រូវសរសេរឲ្យបានច្បាស់នៅក្នុងសាលក្រម ឬ សាលដីការបស់ខ្លួន ។ បើមានការបាត់បង់ ឬបានចំណាយមិនត្រឹមត្រូវ ក្រឡាបញ្ជីដែលត្រូវរក្សាប្រាក់នេះ នឹងត្រូវទទួលខុសត្រូវ ដូចមានចែងក្នុងមាត្រាទី ១៩ នៃច្បាប់ស្ដីពីប្រាក់ប្រដាប់ក្ដី ។

ដោយឡែក ប្រធានតុលាការត្រូវត្រួតពិនិត្យជាប្រចាំអំពីសកម្មភាពរបស់ក្រឡាបញ្ជីកាន់ហឹបប្រាក់ ដោយចាត់វិធានការយ៉ាងតឹងរ៉ឹង ដើម្បីគ្រប់គ្រងប្រាក់នេះឲ្យបានល្អ ។

ចៅក្រមណាមួយដែលទទួលជំនុំជម្រះរឿងដោយឥតឲ្យគូក្ដីបង់ប្រាក់ប្រដាប់ក្ដី ចៅក្រមនោះត្រូវទទួលខុសត្រូវអំពីការបាត់បង់ប្រាក់ប្រដាប់ក្ដីនេះ ។

អំណើះតទៅ ក្រសួងយុត្តិធម៌ នឹងមានចាត់អ្នកជំនាញឲ្យមកត្រួតពិនិត្យដល់មូលដ្ឋាន ដោយមិនឲ្យដឹងជាមុន។ បើឃើញថា ការគ្រប់គ្រងនិងថែរក្សាប្រាក់ប្រដាប់ក្ដីប្រព្រឹត្តទៅមិនបានល្អ ក្រសួងនិងមានវិធានការយកច្បាប់ ស្ដីពីការចាត់តាំង និងសម្មភាពរបស់សាលាជម្រះក្ដីនៃកម្ពុជា ត្រង់ជំពូកទី ៦ មកអនុវត្តលើចៅក្រម ឬលើក្រឡាបញ្ជីខុសឆ្គង ។

អស់លោកចៅក្រម និងក្រឡាបញ្ជីទាំងអស់ ត្រូវអនុវត្តោឲ្យបានល្អ សារាចរណែនាំនេះ ដើម្បីជាប្រយោជន៍ ក្នុងការពង្រឹងនីត្យានុកូលភាព ។

ភ្នំពេញ ថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៣

**រដ្ឋមន្ត្រី**

**ចែម ស្ងួន**

<u>ចម្លងជូន:</u>

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-សភាជម្មនុញ្ញ

-ក្រសួងហិរញ្ញវត្ថុ

-អភិបាលខេត្ត ក្រុង

-ដើម្បីជ្រាបជាពត៌មា